# របាយការណ៍
# សិក្ខាសាលាពិគ្រោះយោបល់
# ស្តីពី
# ការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ









## លេខាធិការដ្ឋានរេដបូកកម្ពុជា

ថ្ងៃទី២០ ដល់ ២១ ខែឧសភា ឆ្នាំ២០១៥

សណ្ឋាគារខ្សាច់មាស  ខេត្តព្រះសីហនុ

## សេចក្តីផ្តើម

យុទ្ធសាស្ត្ររេដបូកជាតគឺជាឯកសារគោលនយោបាយយ៉ាងសំខាន់មួយដែលនឹងផ្តល់នូវទិសដៅយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំសម្រាប់អនុវត្តន៍សកម្មភាពរេដបូក។ យុទ្ធសាស្ត្ររេដបូកជាតិក៏ដូចជាយុទ្ធសាស្ត្រផ្សេងៗទៀតដែរ គឺកំណត់នូវបុព្វហេតុនៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ និងរៀបចំគោលនយោបាយជាតិ និងវិធាន ចាំបាច់មួយចំនួនដើម្បីកាត់បន្ថយនូវបុព្វហេតុនៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើដែលសកម្មភាពទាំងនេះ ឈានទៅដល់ការវាស់នូវបរិមាណនៃកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ការអភិរក្ស និងបង្កើនបរិមាណការបូនដែលផ្ទុកនៅក្នុងព្រៃឈើ។

យោងតាមការសម្រេចរបស់ប្រទេសដែលជាភាគីនៃក្របខណ្ឌអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ជាពិសេសនៅក្នុងកិច្ចព្រមព្រៀង ខេនខូន និងក្របខណ្ឌវ៉ារស(Warsaw) សម្រាប់ យុទ្ធសាស្ត្ររេដបូកជាតិ គឺជាតម្រូវការដំបូងបង្អស់សម្រាប់ប្រទេសដែលត្រូវអនុវត្តរេបូក ដូចជាប្រទេសកម្ពុជា ដើម្បី ឈានដល់ការទទួលបានការទូទាត់ហិរញ្ញប្បទានផ្អែកលើលទ្ធផល (Result-based finance) សម្រាប់អនុវត្តន៍គោល នយោបាយ និងវិធានរេដបូក។ តម្រូវការសំខាន់ផ្សេងៗទៀតសម្រាប់ការទូទាត់ហិរញ្ញប្បទានផ្អែកលើលទ្ធផល រួមទាំង ឯកសារជាតិស្តីពីប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិ កម្រិតបំភាយយោង និងប្រព័ន្ធព័ត៌មានសុវត្ថិភាពរេដបូក។

គោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលកម្ពុជា គឺអោយមានយុទ្ធសាស្ត្ររេដបូកជាតិមួយដែលមានការទទួល ស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងបរិស្ថាន បន្ទាប់មកនឹងមានការទទួលស្គាល់ពីទីស្តី
ការគណៈរដ្ឋមន្ត្រី មុនពេលកិច្ចប្រជុំប្រទេសជាភាគី នៅទីក្រុងប៉ារីស ប្រទេសបារាំង ក្នុងខែធ្នូ ឆ្នាំ២០១៥ខាងមុខនេះ។

ដោយយុទ្ធសាស្ត្ររេដបូកជាតិនឹងដាក់អោយអនុវត្តនៅក្នុងវិស័យព្រៃឈើ និងវិស័យផ្សេងៗដែលពាក់ព័ន្ធ វាមានសារៈសំខាន់ណាស់ដែលអ្នកពាក់ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិមានឱកាសគ្រប់គ្រាន់ ដើម្បីចែករំលែកនូវមតិយោបល់និងបទពិសោធន៍របស់ពួកគេ ទៅលើសេចក្តីព្រៀងនៃយុទ្ធសាស្ត្ររេដបូកជាតិ មុនពេលយុទ្ធសាស្ត្ររេដបូក ជាតិទទួលស្គាល់ពីរាជរដ្ឋាភិបាលកម្ពុជា ដូចនេះទស្សនៈរបស់អ្នកពាក់ព័ន្ធនានាត្រូវបានដាក់រួមបញ្ចូលលទៅក្នុង ឯកសារដ៏មានសារៈសំខាន់នេះ។ ដើម្បីអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិទទួលបានជោគជ័យនិងមានប្រសិទ្ធិភាពតម្រូវ អោយមានការគាំទ្រ និងចូលរួមយ៉ាងលេញពីអ្នកពាក់ព័ន្ធនានាទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងអ្នកពាក់ព័នផ្សេងៗទៀត។

នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ ពង្រាងយុទ្ធសាស្ត្ររេដបូកជាតិលើកទី១ត្រូវបានរៀបចំឡើងដែលឯកសារនេះបានផ្ញើរជូនក្រុមអ្នកជំនាញការរេដបូកដើម្បីពិនិត្យ និង ផ្តល់យោបល់កែសម្រួលដែលសមាជិកក្រុមអ្នកជំនាញមានចំនួន ១១នាក់ (ទាំងអ្នកជំនាញជាតិ និងអន្តរជាតិ)។ យោបល់ និងអនុសាសន៍ដែលបានផ្តល់ដោយក្រុមអ្នកជំនាញការត្រូវបានប្រមូលចងក្រង និងបន្ថែមពីនេះទៀតពង្រាងយុទ្ធសាស្ត្ររេដបូកជាតិលើកទី១ត្រូវបានចែករំលែកដល់អ្នកពាក់ព័ន្ធ សំខាន់ៗផ្សេងទៀត ជាពិសេសមន្ត្រីជំនាញរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន។ នៅដំណាច់ខែមីនា ឆ្នាំ២០១៥ យោបល់ទាំងឡាយដែលបានផ្តល់និងកែសម្រួលទៅលើសេច

ក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិលើកទី១ត្រូវបានប្រមូលពីអ្នកជំនាញផ្នែករេដបូក និងមន្ត្រីជំនារញពាក់ព័ន្ធ និងទីប្រឹក្សា បានការកែសម្រួលនិងបានរៀបចំពង្រាងយុទ្ធសាស្ត្ររេដបូកជាតិលើកទី២។ បន្ថែមពីនេះទៀតឯកសារបានរៀបចំទន្ទឹមគ្នានឹងពង្រាងយុទ្ធសាស្ត្ររេដបូកជាតិផងដែរ។ ឯកសារត្រូវបានរៀបចំដើម្បីចងក្រងនូវមតិយោបល់ពីអ្នកពាក់ព័ន្ធ និងចំណុចសំខាន់ៗដែលបានឆ្លើយតបរាល់អនុសាសន៍ និងមតិយោបល់ទាំងនោះ។

យោងតាមកិច្ចពិភាក្សាជាមួយមន្ត្រីជំនាញដែលពាក់ព័ន្ធ និងផែនការរបស់រដ្ឋាភិបាលកម្ពុជាដើម្បីអោយមានពង្រាងយុទ្ធសាស្ត្ររេដបូកជាតិចុងក្រោយមុនកិច្ចប្រជុំភាគីនៅទីក្រុងប៉ារីសគឺរំពឹងថាសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិទី៣ នៅដំណាច់ខែមិថុនា និង ពង្រាងយុទ្ធសាស្ត្ររេដបូកជាតិទី៤ និងត្រូវបញ្ចប់រចរាល់នៅក្នុងខែកក្កដា និង ពង្រាងយុទ្ធសាស្ត្ររេដបូកជាតិចុងក្រោយនៅក្នុងខែសីហា ឆ្នាំ២០១៥។

ហេតុដូច្នេះ ទើបរវាងខែឧសភា និងខែសីហា ឆ្នាំ២០១៥ យុទ្ធសាស្ត្ររេដបូកជាតិ និងចំណុចដែលត្រូវគូសបញ្ជាក់នៅក្នុងឯកសារប្រវត្តិ នឹងត្រូវយកមកពិគ្រោះយោបល់ជាមួយក្រុមអ្នកពាក់ព័ន្ធ ដូចជា ក្រុមការងាររេដបូកកម្ពុជា ក្រុមប្រឹក្សាយោបល់ ក្រុមការងារច្ចេកទេសទាំង៤ក្រុម (ប្រព័ន្ធធានាសុវត្ថិភាពរេដបូក ចែករំលែកផលប្រយោជន៍ ត្រួតពិនិត្យ រាយការណ៍ និងផ្ទៀងផ្ទាត់ និងក្រុមការងារអនុវត្តគំរូ) ក្រុមការងារយេនឌ័រ និងក្រុមអ្នកពាក់ព័ន្ធផ្សេងៗទៀត។ កិច្ចប្រជុំពិគ្រោះយោបល់នេះនឹងប្រើប្រាស់ជាវេទិការសម្រាប់ផ្តល់ឱកាសអ្នកពាក់ព័ន្ធដើម្បីផ្តល់អនុសាសន៍ជំនាញបច្ចេកទេស និងបញ្ហាផ្សេងៗទៅលើយុទ្ធសាស្ត្ររេដបូកជាតិ។ គួរបញ្ជាក់ផងដែររាល់កិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធលើយុទ្ធសាស្ត្ររេដបូកជាតិត្រូវបានចងក្រងជាឯកសារដែលនឹងគូសបង្ហាញនៅក្នុងឯកសារប្រវត្តិដើម្បីធានាថាដំណើរការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ គឺមានតម្លាភាពការចូលរួមនិងការទទួលខុសត្រូវ។

**គោលបំណង**

គោលបំណងជាក់លាក់សម្រាប់កិច្ចប្រជុំពិគ្រោះយោបល់នឹងផ្អែកទៅលើពង្រាងឯកសារនីមួយៗដែលនឹងត្រូវដាក់ពិគ្រោះយោបល់។ ជារួមរាល់ការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់យុទ្ធសាស្ត្ររេដបូកជាតិនីមួយៗ មានគោលបំណងដូចខាងក្រោម៖

- បង្ហាញពីស្ថានភាពនៃការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ ដំណើការ និងគូសបញ្ជាក់នូវអនុសាសន៍ដែលជាតម្រូវការ ឬ ការសម្រេចចិត្ត(ឧទាហរណ៍ ទំហំនៃការអនុវត្តរេដបូក, បុព្វហេតុដែលបណ្តាលអោយមានការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើ , គោលនយោបាយ និងវិធាន, ។ល។)
- ប្រមូលអនុសាសន៍ដែលមានលក្ខណៈបច្ចេកទេសនិងបញ្ហាប្រឈមនានា ពីអ្នកចូលរួម និងអ្នកបច្ចេកទេសដែលអនុសាសន៍ ននឹងដាក់បញ្ចូលទៅក្នុងពង្រាងយុទ្ធសាស្ត្ររេដបូកជាតិ។
- កំណត់ពីគោលបំណងនៃអនុសាសន៍ និងតម្រូវការនានានៃ ដើម្បីធ្វើការកែសម្រួលសេចក្តីព្រាងយុទ្ធសាស្រ្តរេដបូកជាតិ។

**សុន្ទរកថាបើកអង្គសិក្ខាសាលារបស់អ្នកស្រី វង្ស សុបញ្ញា** អនុប្រធានរដ្ឋបាលព្រៃឈើជាប្រធានក្រុមការងារយេនឌ័រ (Gender) និងជាតំណាងឱ្យឯកឧត្តមជាសំអាងប្រធានក្រុមការងាររេដបូកកម្ពុជា មានអត្ថន័យនិងខ្លឹមសារសំខាន់ៗដូចខាងក្រោម៖

- រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថាយន្តការរេដបូក គឺជាយន្តការមួយក្នុងចំណោមយន្តការផ្សេងៗដែលអាចជួយការពារព្រៃឈើ និងរក្សាបរិមាណកាបូនស្តុកនៅក្នុងព្រៃឈើ ចូលរួមទប់ស្កាត់ការបាត់បង់ព្រៃឈើ និងចូលរួមចំណែកកាត់បន្ថយនូវភាពក្រីក្ររបស់សហគមន៍មូលដ្ឋានរស់នៅតាមតំបន់ព្រៃឈើតំបន់ការពារធម្មជាតិនិងតំបន់ជនបទ។
- ប្រទេសកម្ពុជាមានគោលនយោបាយជាច្រើនក្នុងការគ្រប់គ្រងព្រៃឈើ ដើម្បីធានាអោយបាននូវការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាពនិងចីរភាពគោលនយោបាយទាំងនោះគឺជាមូលដ្ឋានក្នុងការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ និងឯកសារផែនទីបង្ហាញផ្លូវរេដបូកកម្ពុជាក្នុងការអនុវត្ត។
- សិក្ខាសាលាពិគ្រោះយោបល់មានសារៈសំខាន់ក្នុងកាប្រមូលអនុសាសន៍ និងមតិយោបល របស់អ្នកពាក់ព័ន្ធ ធ្វើយ៉ាងណាដើម្បីអោយការៀបចំយុទ្ធសាស្រេរេដបូកជាតិនេះ និងអនុវត្តឱ្យមានប្រសិទ្ធភាពនិង សញ្ជាក់ផងដែរថា ដំណើការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ គឺមានការចូលរួមពេញលេញ និងបានឆ្លុះបញ្ជាំងនូវយោបល់អ្នកពាក់ព័ន្ធនានា។
- យុទ្ធសាស្ត្ររេដបូកជាតិគឺជាឯកសារគោលនយោបាយយ៉ាងសំខាន់មួយដែលជាត្រីវិស័យមួយផ្តល់នូវទិសដៅយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំសម្រាប់អនុវត្តសកម្មភាពរេដបូកនៅក្នុងប្រទេស។
- យុទ្ធសាស្ត្រផ្សេងៗទៀតដែរ យុទ្ធសាស្ត្ររេដបូកជាតិ គឺដើម្បីកំណត់នូវ បុព្វហេតុនៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ និងរៀបចំគោលនយោបាយដ៏សាកសម្ប និងវិធានចាំបាច់មួយ ចំនួនដើម្បីកាត់បន្ថយ នូវបុព្វហេតុនៃ ការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ ដែលសកម្មភាពទាំងនេះឈានទៅដល់ការវាស់នូវបរិមាណ នៃកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ការអភិរក្ស និងបង្កើនបរិមាណការបូនដែលផ្ទុកនៅក្នុងព្រៃឈើ
- គោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលកម្ពុជា គឺអោយមានយុទ្ធសាស្ត្ររេដបូកជាតិមួយដែលមាន ការទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងបរិស្ថាន បន្ទាប់មកនឹងមាន ការទទួលស្គាល់ពីទីស្តីការគណៈរដ្ឋមន្ត្រី មុនពេលកិច្ចប្រជុំប្រទេសជាភាគី នៅទីក្រុងប៉ារីស ប្រទេសបារាំង ក្នុងខែធ្នូឆ្នាំ២០១៥ខាងមុខនេះ។
- ពង្រាងយុទ្ធសាស្ត្ររេដបូកជាតិលើទី២ បានរៀបចំឡើងនេះនឹងប្រើប្រាស់ជាឯកសារគ្រឹះនៅក្នុងកិច្ចពិភាក្សា។ យុទ្ធសាស្ត្ររេដបូកជាតិនេះកើតចេញពី បណ្តុំលទ្ធផលនៃ ការសិក្សា វាយតម្លៃ កិច្ចប្រជុំពិគ្រោះយោបល់ ការសម្របសម្រួលរៀបចំស្ថាប័នជំនាញ និងបទពិសោធន៍នៃការអនុវត្តរេដបូកដែលបានអនុវត្តនៅក្នុងជំហានត្រៀមខ្លួន (២០១០-២០១៤)។
- កិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធលើសយុទ្ធសាស្ត្ររេដបូកជាតិនឹងចងក្រងជាឯកសារ ដែលនឹងគូសបង្ហាញនៅក្នុងឯកសារប្រវត្តិ (Background Document) ដើម្បីធានាថាដំណើការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ គឺតម្លាភាពការចូលរួម និងមានការទទួលខុសត្រូវទាំងអស់គ្នា។

**បទបង្ហាញ ស្តីពី អនុសញ្ញាក្រមខណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងយន្តការរេដបូក ដោយលោក Joel Scriven ទីប្រឹក្សាបច្ចេកទេសថ្នាក់តំបន់របស់អង្គការ UNDP បានបង្ហាញនូវចំនុច សំខាន់ៗដូចខាងក្រោម៖**( ឧបសម្ព័ន្ធ I )

- ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុលើ មនុស្ស សត្វ និងធម្មជាតិ
- បរិមាណការបំភាយឧស្ម័នកាបូនិចដោយសកម្មភាពមនុស្ស(២០០៣-២០១៣)
- អនុសញ្ញាក្រមខណ្ឌអង្គការសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ និងយន្តការរេដបូក ជាលក្ខណៈសកល។
- បង្ហាញពីបរិមាណការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលចេញពីវិស័យទាំងប្រាំនៅកម្ពុជាតាមរបាយការណ៍ថ្នាក់ជាតិដែលបានដាក់ជូនអង្គការសហប្រជាជាតិ (Cambodia National-Communication report)
- សកម្មភាពដែលអាចអនុវត្តក្រោមយន្តការរេដបូក៖ (១)ការកាត់បន្ថយការបំភាយឧស្ម័នដែលបណ្តាលមកពីការបាត់បង់ព្រៃឈើ, (២)ការកាត់បន្ថយការបំភាយឧស្ម័នដែលបណ្តាលមកពីរេចរឹលព្រៃឈើ, (៣)ការអភិរក្សការបូនស្តុកនៅក្នុងព្រៃឈើ (៤)ការគ្រប់គ្រងព្រៃឈើប្រកដោយនិរន្តរភាព និង(៥)ការបង្កើនបរិមាណបូនស្តុកនៅក្នុងព្រៃឈើតម្រូវការនូវសមាសភាពទាំងបួនដែលអាចអោយប្រទេសដែលអនុវត្តរេដបូកទទួលបានការ ទូទាត់សងផ្អែកលើលទ្ធផល (Result based finance)
- ការគាំទ្រពីអន្តរជាតិ សម្រាប់ការអនុវត្តជំហាននៃការត្រៀមខ្លួនរេដបូកនៅថ្នាក់សកល
- រយៈពេលនៃការត្រៀមលក្ខណៈសម្រាប់អនុវត្តរេដបូកនៅក្នុងប្រទេសកម្ពុជា។

**បទបង្ហាញស្តីពី គោលការណ៍សំខាន់ក្នុងការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ ដោយលោកBruno Hugel ទីប្រឹក្សាបច្ចេកទេសថ្នាក់តំបន់របស់អង្គការ UNDP បានបង្ហាញនូវចំនុចសំខាន់ៗដូចខាងក្រោម៖**(ឧបសម្ព័ន្ធ I)

**សំនួរ និងចម្លើយរបស់អ្នកចូលរួម៖**

**លោកបណ្ឌិត ដោក ដូម៉ា៖** នៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិប្រសិនបើមិនមានការបញ្ជាក់អោយបានច្បាស់ពីបុព្វហេតុនៃការបាត់បង់ព្រៃឈើទេដែលមានជាក់ស្តែងនោះវាពិបាកនឹងទទួលបានការអនុម័តពី រាជរដ្ឋាភិបាល។ ពីព្រោះបុព្វហេតុនៃការបាត់បង់ព្រៃឈើមួយចំនួនទាក់ទងនឹងជាមួយរឿងនយោបាយ ក៏ប៉ុន្តែ ការកើនឡើងនូវចំនួនប្រជាជនប្រហែលជាមិនទាក់ទងនឹងការបាត់បង់ព្រៃឈើទេ។

**លោក ធីត ឈន**៖ តើការរៀបចំយុទ្ធសាស្ត្ររេដជាតិ ប្រទេសកម្ពុជាបានសន្យា ជាមួយ UNFCCC រឺទេ?

**លោក ឈុន ឌីលុច**៖ ចំពោះមុខអន្តរជាតិ ប្រទេសកម្ពុជាមិនមានកាពព្វកិច្ចក្នុងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលចេញមកពីការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើទេ។ ក៏ប៉ុន្តែប្រទេសកម្ពុជាជាប្រទេសហត្ថលេខីនៅក្រោមអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ។ ជាក់ស្តែងនៅ COP ទី១៦?

ប្រទេសឥណ្ឌូនេស៊ី នៅឆ្នាំ ២០០៧ ឯកឧត្តម ម៉ុក ម៉ារេ រដ្ឋមន្ត្រីក្រសួងបរិស្ថានបានប្រកាសថា *"រាជរដ្ឋាភិបាលកម្ពុជា គាំទ្រយ៉ាងខ្លាំងដល់ការដាក់បញ្ចូលការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ (GHG)* ***ពីការអភិរក្សព្រៃឈើ និងការបញ្ចៀសមិនឲ្យមានការបាត់បង់ព្រៃឈើ*** *ក្រោយកិច្ចព្រមព្រៀងក្យូតូ បញ្ចប់"* ។ ប្រទេសកម្ពុជាក៏បានបញ្ជូនគណៈប្រតិភូចូលរួម COP ជារៀងរាល់ឆ្នាំ។

**<u>លោក អ៊ុយ កាម៉ាល់៖</u>** រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងបរិស្ថានជាតំណាងក្នុងការទំនាក់ទំនងជាមួយ UNFCCCជារៀងរាល់ឆ្នាំមុនពេលចូលរួមប្រជុំក្រសួងបរិស្ថានបានរៀបចំសិក្ខាសាលាជាមួយអ្នកពាក់ព័ន្ធដើម្បីរៀបចំ Position Paper នឹងស្នើសុំការអនុម័តពីរាជរដ្ឋាភិបាលមុននឹងធ្វើសេចក្តីប្រកាសជាអន្តរជាតិនៅក្នុងអំឡុងពេល កិច្ចប្រជុំ COP។

**<u>លោក ហេង ហុង</u>**៖ តើប្រទេសណាដែលមានស្ថានភាពដូចប្រទេសកម្ពុជា បានកដំណើរការអនុវត្តយន្តការរេដបូកទទួលជោគជ័យ?

**<u>លោក Bruno Hugel៖</u>** ប្រទេសនីមួយៗមានស្ថានភាពផ្សេងៗគ្នា នេះដោយសារតែ បុព្វហេតុនៃការបាត់បង់ និងរេចរឹលព្រៃឈើ និងការគាំទ្រផ្នែកគោលនយោបាយ។ South-South cooperation ជាយន្តការប្រើប្រាស់នៅក្នុងការចែករំលែកព័ត៌មាន និងបទពិសោធន៍ស្តីពីការអនុវត្តរេដបូកនៅថ្នាក់តំបន់។ រេដបូកជាឱកាសសម្រាប់ប្រទេសនីមួយ ៗក្នុងការទំនាក់ទំនងរកមូលនិធិសម្រាប់ការពារព្រៃឈើ និងប្រទេសទាំងនោះអាចប្រើប្រាស់មូលនិធិដែលទទួលបានពីរេដបូកដើម្បីអភិវឌ្ឍន៍ប្រទេសផងដែរ។

**<u>លោក Joel Scriven៖</u>** ប្រទេសទាំងអស់ដែលកំពុងអនុវត្តរេដបូក គឺស្ថិតនៅក្នុងដំណាក់កាលចាប់ផ្តើមដូចគ្នា ក៏ប៉ុន្តែ ស្ថិតនៅជំហានអនុវត្តន៍ផ្សេងៗគ្នា គឺមិនមានរូបមន្តណាមួយជាក់លាក់ទេក្នុងការអនុវត្តរេដបូកទេ ជាក់ស្តែងប្រទេស Brazil ដែលអនុវត្តរេដបូកនៅក្នុងតំបន់ព្រៃ Amazonia ដែលទទួលបានមូលនិធិខ្នាតធំពីអន្តរជាតិ ដែលមានគ្រប់គ្រងដោយតម្លាភាព មានប្រព័ន្ធ MRV NFMS និងយន្តការគ្រប់គ្រងមូលនិធិច្បាស់លាស់។

**ឯកឧត្តម ជាម ប៉េអាះ** ការចាប់ផ្តើមអនុវត្តន៍រេដបូកគួរតែចាប់ផ្តើមពីថ្នាក់ក្រោមជាតិ ដូចជាប្រទេស Brazil ចាប់
ផ្តើមពីតំបន់ព្រៃ Amazonia។ តើចំនួន GHG ដែលនឹងកាត់បន្ថយនៅក្នុងប្រទេស Brazil មានជះឥទ្ធិពលដល់សហគមន៍មូលដ្ឋានដែរឬទេ? សម្រាប់ប្រទេសកម្ពុជា ប្រសិនបើទំហំនៃការអនុវត្តរេដបូក នឹងមានឥទ្ធិពលដល់សហគមន៍មូលដ្ឋានទេ? ចំពោះប្រទេសអភិវឌ្ឍន៍ តើពួកគេចូលរួមកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ដោយរបៀបណា? (ទំហំ វិសាលភាព ការអនុវត្ត និង តួនាទី)

**<u>លោក Bruno Hugel៖</u>** ចំពោះទំហំ និងវិសាលភាព វាអាស្រ័យទៅលើប្រទេសនីមួយៗ ថាតើរេដបូកឆ្លើយតបសម្រាប់ប្រទេសទាំងនោះដែរឬទេ?។ ការអនុវត្តរេដបូកគឺតាមវិធីសាស្ត្រដ៏ត្រឹមត្រូវមួយ (stepwise approach) ។ ប្រទេស Brazil ដែលចាប់ផ្តើមការអនុវត្តនៅតំបន់ Amazon ដោយសារតំបន់នោះមានការបំភាយឧស្ម័នផ្ទះកញ្ចក់ខ្លាំងជាងគេ ដូចនេះយើងពិនិត្យមើលតំបន់ណាដែលមានការបាត់បង់ព្រៃឈើកើតឡើងខ្លាំងជាងគេ។ ទោះបីប្រទេសមួយចំនួនមិនទាន់បានបានចាប់ផ្តើមអនុវត្តរេបូកថ្នាក់ជាតិ តែប្រទេសទាំងនោះបានអនុវត្តរេដបូកនៅលើផ្ទៃធំទូលំទូលាយ ឬទ្រង់ទ្រាយធំនៃប្រទេស។ យន្តការរេដ គឺជាយន្តការមួយមិនហាមឃាត់ប្រជាជនមិនអោយប្រើប្រាស់ធនធានព្រៃឈើនោះទេ ប៉ុន្តែវាបានចូលរួមចំណែកនៅក្នុងគោលដៅការអភិវឌ្ឍន៍ប្រទេស។ នៅក្នុងប្រទេស Brazil រដ្ឋាភិបាលមានការប្តេជ្ញាខ្ពស់ និងមានករសហការល្អរវាងស្ថាប័នផ្សេងៗនៃរដ្ឋាភិបាល ដែលជាចំនុចល្អឈានដល់ការអនុវត្តរេបូកបានជោគជ័យ។ដូច្នេះប្រទេស Brazil បានកាត់បន្ថយការបាត់បង់ព្រៃឈើ និងការអភិវឌ្ឍប្រទេសមានការប្រសើរឡើង។

**<u>អ្នកស្រី វង្ស សុបញ្ញា៖</u>**ការវិនិយោគលើរេដបូក ក្នុងនោះអាចមាន (១)Oversee Development Add (២)ថវិការាជរដ្ឋាភិបាល និង(៣)វិស័យឯកជន។ តើមានប្រទេសប៉ុន្មានដែលរៀបចំយុទ្ធសាស្ត្ររេដបូកជាតិ? តើមានប្រទេសប៉ុន្មានដែលមានយុទ្ធសាស្ត្ររេដបូកជាតិ ហើយទទួលបានមូលនិធិក្នុងការអនុវត្ត? តើមានយុទ្ធសាស្ត្ររេដបូកជាតិដែលមិនបានទទួលបានថវិកាក្នុងការអនុវត្តដោយសារកត្តាអ្វី?

**<u>លោក Bruno Hugel៖</u>** យើងមិនទាន់មាតួលេខជាក់លាក់នឡើយទេ។ ប្រទេសនីមួយៗស្ថិតនៅដំណាក់កាលផ្សេងៗគ្នា នៃការត្រៀមខ្លួនសម្រាប់អនុវត្តរេដបូក។ ប្រទេសជច្រើនបានទទួល ODA នៅក្នុងដំណាកកាលត្រៀមខ្លួន។ ប្រទេស វៀតណាម ប្រេស៊ីល ឥណ្ឌូនេស៊ី និង កង់ហ្គូ បានទទួលហិរញ្ញប្បទានពីរេបូក។ វាអាស្រ័យលើសារៈសំខាន់ឯកសាររបស់យុទ្ធសាស្ត្ររេដបូកជាតិ ថាតើអាចមានប្រសិទ្ធិភាពអនុវត្តបានកម្រិតណា? តើប្រទេសនីមួយៗអាចដោះស្រាយបញ្ហាពិតប្រាកដបានដែរឬទេ?ប្រសិនបើយុទ្ធសាស្ត្ររេដបូកជាតិមានសារៈសំខាន់នឹងមានឱកាសទទួលការគាំទ្រផ្នែកមូលនិធិ។

**<u>បទបង្ហាញ ស្តីពី ភាពរីកចម្រើនលើដំណើររៀបចំយុទ្ធសាស្ត្ររេដបូកជាតិកម្ពុជាដោយលោក ឈុន ឌឺលុ</u>**

(**ឧបសម្ព័ន្ធ I** )

- សេចក្តីព្រាងគ្រោងឆ្អឹងយុទ្ធសាស្ត្ររេដបូជាតិ (បញ្ចប់ ៣០ សីហា ២០១៤)
- រៀបសេចក្តីព្រាងលើទី១ (បញ្ចប់ ០៥ មករា ២០១៥)
- រៀបចំបកប្រែជាភាសាជាតិ (បញ្ចប់ ០៥ កុម្ភៈ ២០១៥)រៀបចំកែសម្រួលយោបលទទួលបានពីក្រុមអ្នកជំនាញរេដបូក (១៦ កុម្ភៈ ២០១៥)
- ប្រជុំជាមួយអ្នកមានសិទ្ធិធ្វើការសម្រេចចិត្ត និងអ្នកជំនាញ (មីនា ២០១៥)

- រៀបចំសេចក្តីព្រាងលើទី២ (បញ្ចប់ ១០ មេសា ២០១៥)
- រៀបចំបកប្រែជាភាសាជាតិ (បញ្ចប់ ០៨ ឧសភា ២០១៥)
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើទី១ ជាមួយក្រុមការងារ និងក្រុមច្ចេកទេស(TF, TTs , CG, &GG) (២០-២១ ឧសភា ២០១៥)

<u>**សំនួរ និងចម្លើយរបស់អ្នកចូលរួម៖**</u>

<u>**លោក សុខ ពិសិដ្ឋ៖**</u> គួរប្រើប្រាស់ទិន្នន័យដែលមានបច្ចុប្បន្ននៅក្នុងយុទ្ធសាស្រ្តរេដជាតិជាពិសេសព័ត៌មានការបាត់ បង់ព្រៃឈើ និងការថយចុះព្រៃឈើ។

<u>**លោក សា ថ្លៃ៖**</u> ចំពោះនិយមព្រៃឈើ ដែលប្រើនៅក្នុងយុទ្ធសាស្រ្តរេដបូកជាតិ គឺសំដៅព្រៃដាំឬ ធម្មជាតិ ព្រោះ Cancun បានកំណត់អោយអនុវត្តរេដបានតែនៅក្នុងតំបន់ព្រៃធម្មជាតិ។

<u>**លោក វ៉ា មឿន៖**</u> ចំពោះការប្រើប្រាស់ទិន្នន័យនៅក្នុងឯកសារនេះជាតួលេខចាស់ៗដែលបានប្រើប្រាស់យូរឆ្នាំមក ហើយ ចំពោះទិន្នន័យមួយចំនួនទាក់ទងនិងនយោបាយ ឬទិន្នន័យមិនច្បាស់លាស់ធ្វើជាគោល ដើម្បីឈានដល់កំណត់គោលដៅ ដូចជា ការរៀបចំសហគមន៍ព្រៃឈើអោយបានចំនួន ២លានហិកតា នៅដំណាច់ឆ្នាំ ២០២៩ ប៉ុន្តែជាក់ស្តែងពេលបច្ចុប្បន្ន មាន ៦០០០០ ហិចតា ចំនួន ៤០០សហគមន៍ តែមានសហគមន៍មួយចំនួនបានបាត់បង់ព្រៃឈើរួចមកហើយ។ ចំពោះទិសដៅនៃការបង្កើតសហគមន៍រហូតដល់ ២លាន ហិចតានៅតំណាច់ឆ្នាំ ២០២៩ ប្រហែលជាមិនអាចអនុវត្តបានសម្រេចទេ។

<u>**លោក Joel Scriven៖**</u> នៅក្រោមយន្តការរេដបូក ព្រៃដាំអាចរាប់បញ្ចូលនៅក្រោមយន្តការរេដបូកបាន ប៉ុន្តែមិនអាចទទួលការទូទាត់សងបានទេ ប្រសិនបើយើងបំលែង រឺកាប់ឆ្ការព្រៃធម្មជាតិហើយដាំព្រៃឈើឡើង។ក៏ប៉ុន្តែផ្ទុយមកវិញ ប្រសិនបើយើងមានណាតំបន់ដែលបានស្ថាភាពព្រៃរេចរឹល ហើយបានដាំស្តារព្រៃនៅលើតំបន់រេចរឹលទាំងនោះ យើងអាចចាត់ទុកជាតំបន់ព្រៃឈើហើយអាចអនុវត្តរេដបូកបាននៅលើតំបន់នោះ។

<u>**លោក ឈុន ឌីលុច៖**</u> ទិន្នន័យដែលបានកំពុងប្រើនៅក្នុងការរៀបចំសេចក្តីព្រាងយុទ្ធសាស្រ្តរេដបូកជាតិនេះ គឺផ្អែកលើទិន្នន័យរបស់រាជរដ្ឋាភិបាលដែលប្រើប្រាស់ចុងក្រោយ។ ក្នុងការរៀបចំយុទ្ធសាស្រ្តរេដបូកជាតិមិនចាំបាច់រៀប រាប់នូវព័ត៌មានលំអិតនោះទេ យើងគ្រាន់តែរៀបចំក្នុងទម្រង់ជាយុទ្ធសាស្រ្តប៉ុណ្ណោះ។ ចំពោះព័ត៌មានលម្អិតមានបញ្ជាក់នៅក្នុងឯកសារ FREL/REL និងNFMS។

<u>**លោក ទ្បេង ជីវិន៖**</u> យើងគួរតែបញ្ជាក់ទិន្នន័យដែល ចាស់ៗ និងទិន្ន័យចុងក្រោយអោយច្បាស់។ បច្ចុប្បន្នយើងមានទិន្នន័យគម្របព្រៃឆ្នាំ២០១០ គឺជាទិន្នន័យចុងក្រោយគេរបស់ប្រទេសកម្ពុជា បច្ចុប្បន្នយើងកំពុងធ្វើការបកស្រាយគម្របព្រៃឆ្នាំ២០១៤/២០១៥។ នៅក្នុងការចចារេដបូក គេធ្វើការចាត់ថ្នាក់ជា បី Tires ប្រទេស

នីមួយៗអាចជ្រើសរើសយក Tire ក្នុងកម្រិតណាមួយមកអនុវត្តបាន។ ចំពោះ Tire 2 តម្រូវអោយប្រើប្រាស់ទិន្នន័យចុងក្រោយគេដែលប្រទេសនីមួយៗមាន។ សម្រាប់ការអោយនិយមន័យព្រៃឈើ យើងនិងរៀបចំនិយមន័យព្រៃឈើមួយទៀតសម្រាប់អនុវត្តនៅក្នុងយន្តការរេបូក និយមន័យមានលក្ខណៈស្រដៀងគ្នានិងនិមយន័យដែលបានកំពុងប្រើប្រាស់ក្នុងកម្មវិធីព្រៃឈើជាតិ តែមិនបានរាប់បញ្ចូល ព្រៃកៅស៊ូដាំ និងដូងប្រេងចូលជាព្រៃឈើឡើយ។ ជារួមដោយសារយន្តការរេដបូកជាយន្តការអន្តរជាតិដូចនេះ រាល់ការរៀបចំ និងវាយតម្លៃនានាត្រូវបំពេញតាមតម្រូវការអន្តរជាតិ។

<u>**បទបង្ហាញ ស្តីពី ការរៀបចំក្រុមពិភាក្សា លើ ទំហំ (Scope), វិសាលភាព (Scale) និងបុព្វហេតុដែលបណ្តាលអោយមានការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើ ដោយលោក ឈុន ឌីលុច**</u>

ក្រុមទី១៖ ក្រុមការងាររេដបូកម្ពុជាសម្របសម្រួលដោយលោក ឈុន ឌីលុច និងសមាជិកក្រុមម្នាក់

ក្រុមទី២៖ ក្រុមបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាពរេដបូក ក្រុមការងារយេនឌ័រ និង ក្រុមប្រឹក្សាយោបល់ សម្របសម្រួលដោយលោក ជា ណារ៉េត និងសមាជិកក្រុមម្នាក់

ក្រុមទី៣៖ ក្រុមបច្ចេកទេសលើការបែងចែកផលប្រយោជន៍ ក្រុមការងារយេនឌ័រ និង ក្រុមប្រឹក្សាយោបល់សម្របសម្រួលដោយលោក ហេង ហុង និងសមាជិកក្រុមម្នាក់

ក្រុមទី៤៖ ក្រុមបច្ចេកទេស MRV / FREL ក្រុមការងារយេនឌ័រ និងក្រុមប្រឹក្សាយោបល់សម្របសម្រួលដោយលោក ឡេង ជីវិន និងសមាជិកក្រុមម្នាក់។

អ្នកសម្របសម្រួលបានផ្តល់សំនួរគោលសម្រាប់កិច្ចពិភាក្សាដល់ក្រុមនីមួយៗដូចខាងក្រោម៖

<u>**ក្រុមពិភាក្សាប្រធានបទ ស្តីពី Scope និង Scale ក្នុងការអនុវត្តរេដបូកនៅប្រទេសកម្ពុជា**</u>

**សំនួរគោល**៖ តើយុទ្ធសាស្ត្ររេដបូកជាតិនឹងដោងស្រាយសកម្មភាពមួយណា? (១)ការបាត់បង់ព្រៃឈើ (២)ការរេចរឹលព្រៃឈើ (៣)ការគ្រប់គ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព (៤)ការបង្កើនបរិមាណសន្និធិកាបូន (៥)អភិរក្សសន្និធិកាបូន? តើកម្ពុជាគួរអនុវត្តសកម្មភាពទាំងនេះនីកម្រិតជាតិ រឺថ្នាក់ក្រោមជាតិ រឺកម្រិតគម្រោ?

<u>**លទ្ធផលក្រុមពិភាក្សា ស្តីពី ការកំណត់ សកម្មភាពរេដបូក Scope និង Scale ក្នុងការអនុវត្តរេដបូកនៅប្រទេសកម្ពុជា**</u>

**ក្រុមការងាររេដបូកកម្ពុជា៖**

**សម្របសម្រួលដោយលោក ឈុន ឌីលុច**

| **សកម្មភាពរេដបូក** | **ទំហំ/វិសាលភាព** |
|---|---|
| • យុទ្ធសាស្ត្ររេដបូកជាតិ គួដោះស្រាយ <u>សកម្មភាព រេដបូកទាំង ៥</u> ប៉ុន្តែគួរ កំណត់ | <u>**ទំហំ/វិសាលភាព៖**</u> ក្នុងការរៀបចំយុទ្ធសាស្ត្ររេដបូកគឺគិតនៅកម្រិតជាតិ ជំហាននៃការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិត្រូវធ្វើទៅតាមដំណាក់កាល និង |

| | |
|---|---|
| សកម្មភាពដែលជាអទិភាពដើម្បីដោះស្រាយជាដំបូង ដែលស្ថិតនៅក្នុងពេលវេលមួយជាក់លាក់<br><br>• <u>ការបាត់បង់ព្រៃឈើគួរដោះស្រាយមុនគេ</u> ហើយគួបញ្ជាក់ថាតើ នៅពេលណាដែលកម្ពុជានឹងដោះសកម្មភាពបន្ទាប់ទៀត នេះគួតែគូសបញ្ជាក់អោយច្បាស់នៅក្នុងយុទ្ធសាស្ត្រជាតិ។<br><br>• សកម្មភាពគួរដោះស្រាយ បន្ទាប់ពីការបាត់បង់ព្រៃឈើកម្ពុជាគួរដោះស្រាយ (១) ការថយចុះនៃព្រៃឈើ (២)ការបង្កើនបរិមាណកាបូនស្តុក និងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព | ដោះស្រាយបុព្វហេតុនៃការបាត់បង់ព្រៃឈើ និងថយចុះនៃព្រៃឈើដែលបានកំណត់ជាអទិភាពនៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិនេះ។ |

**ក្រុមការងារបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាពរេដបូក៖**
**សម្របសម្រួល ដោយកញ្ញា តេង រិទ្ធីនី លោក យៀង ដូណាស់ និងលោក ជា ណារ៉េត**

| **សកម្មភាពរបស់រេដបូក** | **ទំហំ/វិសាលភាព៖** |
|---|---|
| ប្រទេសកម្ពុជាគួរដោះស្រាយ៖<br>១. ការបាត់បង់ព្រៃឈើ ជាអាទិភាព<br>២. ការរេចរឹលព្រៃឈើ ដែលក្នុងនោះមានសកម្មភាពដូចជា៖ ការកាប់ឈើខុសច្បាប់, ការប្រើប្រាស់មិនមានផែនការគ្រប់គ្រងច្បាស់លាស់) | ប្រទេសកម្ពុជាគួរអនុវត្តសកម្មភាពរេដបូក ថ្នាក់ជាតិ (ទូទាំងប្រទេស) និងកំណត់សម្មភាពដែលអាទិភាព និងទីកន្លែងដែលនឹងអនុវត្តអោយបានច្បាស់លាស់ និងគួរអនុវត្តជាដំណាក់កាលៗ ជាពិសេសត្រូវកំណត់តំបន់ជាអាទិភាពណាមួយអនុវត្តមុនគេ។ |

**ក្រុមការងារបច្ចេកទេស MRV៖**
**សម្របសម្រួលដោយ លោក ឡេង ជីវិន**

| **សកម្មភាពរបស់រេដបូក** | **ទំហំ/វិសាលភាព៖** |
|---|---|
| ១. ដោះស្រាយការបាត់បង់ព្រៃឈើ | |

| | |
|---|---|
| ២. សកម្មភាពបង្កើបបរិមាណការបូនស្តុក<br><br>ប៉ុន្តែនៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិគួរបញ្ជាក់ផងដែរថាកម្ពុជាមានសម្ថភាព និងទិន្នន័យប្រើប្រាស់គ្រប់គ្រាន់ក្នុងការគណនាការបំភាយចេញពីការរេចរឹលព្រៃឈើ នោះកម្ពុជានឹងអនុវត្តសកម្មភាពរេដបូកផ្សេងទៀត។ | • ប្រទេសកម្ពុជាគួរអនុវត្តសកម្មភាពរេដបូកនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ប៉ុន្តែចំពោះថ្នាក់ក្រោមជាតិគួរអនុវត្តគោលនយោបាយ និងវិធាននៅថ្នាកក្រោមជាតិ និងទីតាំងណាមួយជាក់លាក់។ ផ្អែកលើបទពិសោធន៍កម្ពុជាអាចពង្រីកសក្តានុពលអនុវត្តថ្នាក់ជាតិ<br><br>• ឧទាហរណ៍៖ វៀតណាម ផ្អែកលើការសម្រេចរបស់រដ្ឋាភិបាល ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។<br><br>• ចំពោះថ្នាក់គម្រោងគួរតែពិចារណាដាក់បញ្ចូលជាមួយ ផែនការអភិវឌ្ឍន៍ថ្នាក់ជាតិ |

**ក្រុមការងារបច្ចេកទេសចែករំលែកផលប្រយជន៍៖**
**សម្របសម្រួលដោយ លោក ហេង ហុង**

| **សកម្មភាពរបស់រេដបូក** | **ទំហំ/វិសាលភាព៖** |
|---|---|
| ១. ការបាត់បង់ព្រៃឈើ<br>២. ការរេចរឹលព្រៃឈើ<br>៣. ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព<br>៤. ការអភិរក្សព្រៃឈើ<br>៥. ការបង្កើនបរិមាណកាបូនស្តុកក្នុងវិសាលភាពព្រៃឈើ<br>៦. សិក្សាស្រាវជ្រាវ តាមដានវាយតម្លៃបម្រែបម្រួលឮគម្របព្រៃឈើ និងកាបូនស្តុក<br>៧. បង្កើនជីវភាពរបស់សហគមន៍មូលដ្ឋាន | ការអនុវត្តរេដបូកគួរ អនុវត្តកម្រិតថ្នាក់ជាតិ ប៉ុន្តែ គួរកំណត់ថាតើសកម្មភាពរេដបូកណាមួយគួរអនុវត្ត និងនៅទីកន្លែងណាពិតប្រាកដ។ ការអនុវត្តជាក់ស្តែងគួរចាប់ផ្តើមពីតំបន់មួយណាជាក់លាក់ មុនពង្រីកវិសាលភាពទូទាំងប្រទេស។ |

**<u>សង្ខេបលទ្ធក្រុមពិភាក្សាទាំងបួន</u>**

| **សកម្មភាពរបស់រេដបូក** | **ទំហំ/វិសាលភាព៖** |
|---|---|

| | |
|---|---|
| • យុទ្ធសាស្ត្ររេដបូកជាតិ គួរដោះស្រាយសកម្មភាព រេដបូកទាំង ៥ ប៉ុន្តែគួរ កំណត់សកម្មភាពដែលជាអទិភាពដើម្បីដោះស្រាយជាដំបូង ដែលស្ថិតនៅក្នុងពេលវេលាមួយជាក់លាក់។<br><br>• សកម្មភាពដែលយុទ្ធសាស្ត្ររេដបូក គួរដោះស្រាយដំបូងគេ គឺ ការបាត់បង់ព្រៃឈើ និង សកម្មភាពបង្កើតបរិមាណកាបូនស្តុប តាមរយៈការស្តារព្រៃឈើ និងដាំឈើឡើងវិញ<br><br>• នៅពេលដែលប្រទេសកម្ពុជាមានសមត្ថភាព បទពិសោធន៍ និងទិន្នន័យគ្រប់គ្រាន់ប្រទេសកម្ពុជានឹងឈានដល់ការអនុវត្តសកម្មភាព ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ការអភិរក្សកាបូនស្តុក និង ការរេចរឹលព្រៃឈើ | • ការអនុវត្តគួរអនុវត្តទូទាំងប្រទេស ដូចនេះ ហើយរាល់ការរៀបចំយុទ្ធសាស្ត្រជាតិរេដបូក ត្រូវរៀបចំថ្នាក់ជាតិ។<br><br>ប៉ុន្តែ<br><br>• សម្រាប់ការអនុវត្ត គោលនយោបាយ និង វិធាន គួរតែអនុវត្តសាកល្បងថ្នាក់ក្រោមជាតិ មុនឈានដល់ការអនុវត្តថ្នាក់ជាតិ គឺត្រូវ កំណត់ទីកន្លែង និងពេលវេលាគោល នយោបាយ និងវិធាន នឹងអនុវត្តកន្លែង ណា។ ធ្វើរបៀបនេះគឺ ដើម្បីទាញយកបទ ពិសោធន៍ បញ្ហាប្រឈម និងភាពងាយស្រួល ដើម្បីឈានដល់ការអនុវត្តទូទាំងប្រទេសនាពេលអនាគត។ |

<u>**សំនួរ និងចម្លើយរបស់អ្នកចូលរួម៖**</u>

<u>**លោក អ៊ុយ កាម៉ាល់៖**</u> តើមានគោលការណ៍ និង Parameters អ្វីខ្លះក្នុងការកំណត់សកម្មភាព ទំហំ និង វិសាលភាពក្នុងការអនុវត្តរេបូក (សមត្ថភាពក្នុងការត្រួតពិនិត្យ ធនធានមនុស្ស ហិរញ្ញប្បទាន និង គោលនយោបាយ)?ទាំងនេះអាចឈានដល់ការសម្រេចចិត្ត។ ប្រទេសកម្ពុជាអាចអនុវត្តសកម្មភាពរេដបូកទាំងប្រាំតែគួរអនុវត្តដោយដំណាក់កាលៗ ក៏ប៉ុន្តែគួរតែកំណត់ថាសកម្មភាពណាគួរអនុវត្តមុនគេក្នុងផែនការរយៈពេលខ្លី ឬវែង។

**លោក ហេង ហុង៖** ចំពោះការប្រើប្រាស់ទិន្នន័យគម្របព្រៃឈើ មានភាពខុសគ្នារវាងទិន្នន័យរបស់រដ្ឋាភិបាល និងទិន្នន័យរបស់អង្គការក្រៅរដ្ឋាភិបាល តើដោះស្រាយដោយរបៀបណា? តើគួរប្រើប្រាស់ទិន្នន័យណា មួយ?

**លោក Joel Scriven៖** ចំពោះវិធីសាស្ត្រនៅក្នុងការធ្វើសារពើភណ្ឌព្រៃឈើថ្នាក់ជាតិ ការប្រើ Gain-Loss អាចធ្វើទៅបានដោយប្រើទិន្នន័យមិនលំអៀង និងEmission Factor។ នៅក្នុងកិច្ចពិភាក្សាពីវិធីសាស្រផ្សេ

ងៗគ្នានៃ IPCC ប្រទេស Annex I មានការគាំទ្រអោយប្រើ Stock-Different វាមានការលំបាកនៅក្នុងការអនុវត្ត។

**លោក Bruno Hugel** ៖ ចំពោះ Scope ទោះបីប្រទេសនីមួយៗចាប់ផ្តើមពីការដោះស្រាយ ការបាត់បង់ព្រៃឈើ និងបង្កើនសមត្ថភាពដោះស្រាយការរេចរឹលនៃព្រៃឈើ ក៏ប៉ុន្តែប្រទេសនីមួយៗគួរកំណត់ថាតើ សកម្មភាពនៃការបាត់បង់ព្រៃឈើណាដែលសំខាន់គួររួមបញ្ចូល។ ការបង្កើនបរិមាណកាបូនស្តុក តាមរយៈការស្តារព្រៃឈើ និងដាំឈើឡើងវិញ ប្រហែលជាមានសារៈសំខាន់សម្រាប់ប្រទេសកម្ពុជា ព្រោះថាមិនចាំបាច់ទាមទាការងារបច្ចេកទេសច្រើនទេ។ទោះបីយ៉ាងណា វាជាកាល្អដែលយើងគួរចាប់ផ្តើមពីសកម្មភាពតូចៗមុននឹងឈានដល់ការពង្រីកវិសាលភាពនាពេលអនាគត។ រេដបូកគួរតែចាប់ផ្តើមពីការដោះស្រាយការបាត់បង់ព្រៃឈើជាមុន បន្ទាប់មកកំណត់ពីទំហំថាតើការបាត់បង់ព្រៃឈើកើតចេញពីកន្លែងណា និងមានទំហំប៉ុន្មាន។

**ថ្ងៃទី២៖ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៥**

**<u>បទបង្ហាញ ស្តីពី សេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកជាតិ(ជំពូកទី១ - ជំពូកទី៤) ដោយ លោក ឈុន ឌីលុច និងក្រុមការងារទីប្រឹក្សាបច្ចេកទេសនឹងបង្ហាញព័ត៌មានលំអិតនៃជំពូកនីមួយៗ (ជំពូកទី៥ ដល់ទី៩) នៃយុទ្ធសាស្ត្ររេដបូកជាតិ៖ (សូមជូនភ្ជាប់បទបង្ហាញនៅក្នុង ឧបសម្ព័ន្ធទី III)</u>**

- ការគ្រប់គ្រងហិរញ្ញប្បទានរេដបូកជាតិ
- ប្រព័ន្ធព័ត៌មានស្តីពី ប្រព័ន្ធធានាសុវត្ថិភាពរេដបូក
- កម្រិតបំភាយយោងព្រៃឈើ
- ប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិ
- ការរៀបចំស្ថាប័ននៅក្នុងការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ

**<u>សំនួរ និងចម្លើយរបស់អ្នកចូលរួម៖</u>**

**<u>លោក វ៉ា មឿន</u>៖** សហគមន៍ព្រៃឈើបានចំណាយធនធានជាច្រើនក្នុងការធ្វើសារពើភណ្ឌធនធាននៅក្នុងព្រៃរបស់ពួកគេ តើនៅក្នុងការរៀបចំ សារពើភណ្ឌថ្នាក់ជាតិបានប្រើនូវទិន្នទាំនោះដែរទេ?

**<u>លោក អ៊ុយ កាម៉ាល់</u>៖** ក្រសួងបរិស្ថានបានរៀបចំ រចនាសម្ព័ន្ធគ្រប់គ្រងថ្មី។ យោងតាមអនុក្រឹត្យលេខ ៥៩ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន ការរៀបចំថ្មីនេះ បាននិរាករណ៍នូវ ក្រុមប្រឹក្សាអភិវឌ្ឍន៍បៃតង ក្រុមប្រឹក្សាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ជីវសុវត្ថិភាព និងជីវចម្រុះ។

**<u>លោក សៅ រ៉ារី៖</u>** ចំពោះការធ្វើសារពើភណ្ឌ ទាក់ទងទៅនឹងការចុះបញ្ជីដីធ្លី។ សារាចររបស់រដ្ឋាភិបាលតម្រូវអោយស្ថាប័នទាំងអស់ធ្វើសារពើភណ្ឌ និងស្នើសុំចុះបញ្ជី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានទទួលសំណើសុំចុះបញ្ជីដីធ្លីជាបណ្តើៗពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ក្នុងការចុះបញ្ជីអចលនទ្រព្យដែលមាននៅក្នុងបញ្ជីសារពើភណ្ឌរបស់ក្រសួងទាំងពីរនោះ ។ ជាការចុះបញ្ជីសុរិយោដីនាពេលបច្ចុប្បន្នក្រសួងកំពុងរៀបចំប្រព័ន្ធព័ត៌មានដីធ្លី វានឹងមានសារៈសំខាន់ណាស់សម្រាប់ជាតិ។

**<u>លោក សុខ ពិសិដ្ឋ៖</u>** ក្នុងការរៀបចំ និងការគ្រប់គ្រងមូលនិធិរេដបូក និងការរៀបចំស្ថាប័នរេដបូក គួរតែរៀនសូត្របទពិសោធន៍ដែលទទួលបានពីកម្មវិធីវិមជ្ឈការ និងសហវិមជ្ឈការ។

**<u>លោក ឡេង ជីវិន៖</u>** ចំពោះទិន្នន័យសារពើភណ្ឌព្រៃឈើដែលប្រមូលដោយសហគមន៍ព្រៃឈើ គឺរដ្ឋបាលព្រៃឈើបានយកមកប្រើប្រាស់ដើម្បីកសាងសារពើភណ្ឌជាតិ យើងក៏បានធ្វើការវាយតម្លៃលើសុក្រឹត្យភាពលើទិន្នន័យទាំងនោះដែរ។

**<u>លោក សៅ រ៉ារី៖</u>** បច្ចុប្បន្នប្រទេសកម្ពុជាមានប្រព័ន្ធចុះបញ្ជីដីច្បាស់លាស់ ទី១ គឺចុះបញ្ជីដីដោយដុំ និងទី២ ចុះបញ្ជីដីដោយប្រព័ន្ធ ប៉ុន្តែទម្រង់ការនៃកាចុះបញ្ជីដីមានបែបបទខុសៗគ្នា ដូចជា ដំណើការការចុះបញ្ជីដីធ្លីជនជាតិដើមភាគតិចដោយប្រើប្រាស់ថវិការរដ្ឋ។

**<u>លោក អ៊ុយ កាម៉ាល់៖</u>** ការអនុវត្តរេដបូកនឹងមានហានីភ័យខ្ពស់ ប្រសិនបើមិនមានប្រព័ន្ធគ្រប់គ្រងដីធ្លីអោយមានភាពច្បាស់លាស់។ ចំពោះសកម្មភាពចុះបញ្ជីដីវិញ គឺស្ថិតនៅក្នុងដំណាក់កាលចាប់ផ្តើមនៅឡើយ នេះយើអាចនិយាយបានថារេដបូកនៅមានហានីភ័យខ្ពស់។ នៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ គួរដោះស្រាយការគ្រប់គ្រង និងរៀបចំផែនការប្រើប្រាស់ដីធ្លី និងការចុះបញ្ជីដីជាអទិភាពសម្រាប់រេដបូក។

**<u>ឯកឧត្តម ជាម ប៉េអោះ</u>** យុទ្ធសាស្ត្ររេដបូកជាតិ គឺជាបរិបទថ្មីសម្រាប់ប្រទេសកម្ពុជា ដូចនេះវាគួរធ្វើយ៉ាងណាអោយស្របតាមគោលនយោបាយ និងច្បាប់របស់ប្រទេសកម្ពុជាទាំងថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។ ចំពោះកម្មវិធី NCDD នៅក្នុងការប្រើថវិកាជាតិ នឹងគាំទ្រដល់ ថវិកាគាំទ្រខេត្ត ឃុំ ស្រុក វិស័យពាក់ព័ន្ធថ្នាក់ខេត្ត និង គាំទ្រថ្នាក់ជាតិដើម្បីចុះពង្រឹងថ្នាក់ខេត្ត។ យុទ្ធសាស្ត្ររេដបូកជាតិបានលើកពីប្រពភថវិកាពី ឯកជន រដ្ឋ និងម្ចាស់ជំនួយ តែមិនបានបង្ហាញពីការចូលរួមពីអាជ្ញាធរដែលដី ។ គណៈអភិបាលខេត្តជាប្រធានគណៈកម្មការក្នុងដំណើរចុះបញ្ជីដីធ្លី និងបែងចែកដី ដែលមានស្ថាប័នពាក់ព័ន្ធជាអ្នកចូលរួម។ សម្រាប់ការរៀបចំស្ថាប័នក្នុងការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ ត្រូវតែមានគណៈកម្មការថ្នាក់ជាតិ គឺនៅកម្រិតរដ្ឋមន្ត្រី នេះជាចំណុចសំខាន់ឈានដល់ការអនុវត្តរេដបូកបានជោគជ័យ និងគូសបញ្ជាក់ពីយន្តការកសាងសមត្ថភាពសម្រាប់អនុវត្តយុទ្ធសាស្ត្ររេដបូកជាតិនេះ។

**<u>កញ្ញា តេង រិទ្ធីនីៈ</u>** គួរតែមានផែនការប្រើប្រាស់ដីច្បាស់ ហើយមានការឯកភាពពីស្ថាប័នពាក់ព័ន្ធ ទើបអាចឈាន ដល់កាដោះស្រាយការបាត់បង់ និងថយចុះនៃព្រៃឈើបាន។ ចំពោះប្រព័ន្ធធានាសុវត្ថិភាព ដែលទាក់ទងនឹងជន ជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន នៅក្នុងយុទ្ធសាស្ត្រជាតិមិនបានបញ្ជាក់ពីរបៀបរៀបចំ និងគោល ការណ៍ណែនាំFPIC? ចំពោះការបណ្តេញចេញដោយគ្មានការស្មគ្រ័ចិត្ត ចុះបើតំបន់នេះជនជាតិដើមភាគតិច រស់នីវាប់រយឆ្នាំ ហើយបច្ចុប្បន្នវាមានតម្លៃសម្រាប់ការអភិរក្ស តើត្រូវធ្វើការបណ្តេញសហគមន៍ដែរឬទេ? តើការ ចូលរួមដោយមានប្រសិទ្ធភាពនឹងធ្វើដោយរបៀបណា វាចាំបាច់គួរមានគោលការណ៍ណែនាំឬរឺទេ?

**<u>ក្រុមពិភាក្សាប្រធានបទ ស្តីពី បុព្វហេតុដែលបណ្តាលអោយមានការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើនៅក្នុង ប្រទេសកម្ពុជា និងគោលនយោបាយ និងវិធាននៅក្នុងដោះស្រាយនូវបុព្វហេតុទាំងនេះ</u>**

## បុព្វហេតុដែលបណ្តាលអោយមានការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើ

**<u>សំនួរគោល</u>**៖ ផ្អែកលើបុព្វហេតុនៃការបាត់បង់ និងរេចរឹលព្រៃឈើដែលបានកំណត់នៅក្នុងឯកសារពាក់ព័ន្ធជាតិ (ឧ. កម្មវិធីព្រៃឈើជាតិ (២០១០-២០២៩), ផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ការពារធម្មជាតិ, ក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់ផលផល, ផែនទីបង្ហាញផ្លូវរេដបូកជាតិ...) តើបុព្វហេតុដែលបណ្តាលអោយមានការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើអ្វីដែលយើងយកមកដោះស្រាយនៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ? តើនៅក្នុងរយៈពេលខ្លី ពេលមធ្យម និងរយៈពេលវែង (ឧ. តាមរយៈជំហានៗ?) គួរតែមានបន្ថែមបុព្វហេតុដែលបណ្តាលអោយមានការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើត្រូវរៀបចំ ឬសិក្សាបន្ថែមទៀត ដើម្បីបន្ថែមទៅលើ ឬ ធ្វើបច្ចុប្បន្នភាពបុព្វហេតុដែលបណ្តាលអោយមានការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើ ដែលបានកំណត់នៅក្នុងគោលនយោបាយ និងវិធានដែលមានស្រាប់?

## គោលនយោបាយ និងវិធាន

**<u>សំនួរគោលៈ</u>**ផ្អែកលើបុព្វហេតុដែលបណ្តាលអោយមានការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើដែលនឹងដោះស្រាយ ថាតើគោលនយោបាយ និងវិធានដែលមានស្រាប់នៅក្នុង(ឧ. កម្មវិធីព្រៃឈើជាតិ (២០១០-២០២៩), ផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ការពារ, ក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់ផលផល, ផែនទបង្ហាញផ្លូវរេដបូកជាតិ...) ដែលបានស្នើឡើងនឹងយកមកដោះស្រាយឬទេ? តើគោលនយោបាយ និងវិធានគ្រប់គ្រាន់ ឬគោលនយោបាយ និងវិធានដែលមានស្រាប់អាចពង្រឹងតាមរយៈយុទ្ធសាស្ត្ររេដបូកជាតិតាមរបៀបណា? តើនឹងត្រូវការគោលនយោបាយ និងវិធានបន្ថែមទៀតទេ? ប្រសិនបើត្រូវការតើគោលនយោបាយ និងវិធានអ្វីខ្លះ?

**លទ្ធផលក្រុមពិភាក្សា ស្តីពី ការកំណត់ និងស្នើឡើងនូវចលករដែលបណ្តាលអោយមានការបាត់បង់ និងថយចុះនៃព្រៃឈើ និងគោលនយោបាយ និងវិធានក្នុងការដោះស្រាយចលករទាំងនេះ**

**ក្រុមការងារបច្ចេកទេស MRV៖**

**បង្ហាញដោយ៖ សេង លាង**

| ចលករដែលបណ្តាលអោយមានការបាត់បង់ និងរេចរឹលព្រៃឈើ | សកម្មភាព គោលនយោបាយ និងវិធានក្នុងការដោះស្រាយចលករទាំងនេះ |
|---|---|
| **ចំណាត់អទិភាពក្នុងការដោះស្រាយ៖**<br>១. សម្បទានដីសេដ្ឋកិច្ច និងសង្គមកិច្ច<br>២. ការរុករានដីព្រៃយកដីធ្វើកសិកម្ម<br>៣. ការកាប់ឈើខុសច្បាប់<br>៤. ភ្លើងឆេះព្រៃ<br>៦. អាជីវកម្មយករ៉ែ<br>(ប៉ុន្តែការរុករករ៉ែមិនប៉ះពាល់ដល់ព្រៃឈើច្រើនទ) | **ក្រសួងកសិកម្ម/រដ្ឋបាលព្រៃឈើ**:<br>• ច្បាប់ស្តីពីព្រៃឈើ<br>• អនុក្រឹត្យពាក់ព័ន្ធ<br>• គោលនយោបាយព្រៃឈើជាតិ<br>• កម្មវិធីព្រៃឈើជាតិ<br>• ផែនទីបង្ហាញផ្លូវរេដបូកជាតិ<br>**ក្រសួងកសិកម្ម/ រដ្ឋបាលជលផល**:<br>• ច្បាប់ស្តីពីជលផល<br>• អនុក្រឹត្យពាក់ព័ន្ធ<br>• ផែនការយុទ្ធគ្រប់គ្រងវិស័យជលផល<br>**ក្រសួងបរិស្ថាន/GDANCP**:<br>• ច្បាប់ស្តីពីកិច្ចការពាបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ<br>• ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ<br>• ព្រះរាជក្រិត្យឆ្នាំ១៩៩៣ ស្តីពីការបង្កើតតំបន់ការពារធម្មជាតិ<br>• ពង្រាងផែនការយុទ្ធសាស្រ្តគ្រប់គ្រងតំបន់ការពារធម្មជាតិ<br>• ផែនការយុទ្ធសាស្រ្តជាតិស្តីពីស្តីពីការប្រែប្រួលអាកាសធាតុកម្ពុជា<br>**MLUMPC**:<br>• ច្បាប់ភូមិបាលឆ្នាំ២០០១<br>• អនុក្រឹត្យពាក់ព័ន្ធ<br>• គោលនយោបាយស្តីពីសេចក្តីព្រាងទូលំទូលាយ |

| | |
|---|---|
| | • គោលនយោបាយស្តីពីសិទ្ធប្រើប្រាស់ដីធ្លីរបស់ជនជាតិដើមភាគតិច<br>• សារាចរណែនាំការចុះបញ្ជីដីរដ្ឋ<br>• ផែនការប្រើប្រាស់ដីឃុំ/សង្កាត់<br>**ក្រសួងរ៉ែ និងថាមពល**<br>• ច្បាប់ស្តីពីការគ្រប់គ្រង និងធ្វើអាជីវកម្មរ៉ែ<br>• ពង្រឹងយុទ្ធសាស្រ្ត គោលនយោបាយតាមរបៀបណា<br>• យន្តការដែលមានស្រាប់<br>• បង្កើន និងកសាងសមត្ថភាពអ្នកពាក់ព័ន្ធ<br>• កសាង និងពង្រឹងសមត្ថភាពផ្នែកបច្ចេកទេសសម្រាប់រយៈពេលខ្លី/វែង<br>**ក្រសួងមហាផ្ទៃ/ អាជ្ញាធរដែនដី**<br>• ច្បាប់គ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង (គណកម្មការគ្រប់គ្រង អភិបាលខេត្តជាប្រធាន) |

**ក្រុមការងារបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាពរេដបូកៈ**
**បង្ហាញដោយៈ យាង ដូណាល់**

| ចលករដែលបណ្តាលអោយមានការបាត់បង់ និងរេចរឹលព្រៃឈើ | សកម្មភាព គោលនយោបាយ និងវិធានក្នុងការដោះស្រាយចលករទាំងនេះ |
|---|---|
| **បុព្វហេតុផ្ទាល់ៈ**<br>• ដីសម្បទានសេដ្ឋកិច្ច និងសង្គមកិច្ច<br>• ការរុករានដីព្រៃយកដីធ្វើកសិកម្ម<br>• ភ្លើងឆេះព្រៃ<br>• ជីកយករ៉ែ<br>• ការកាប់ឈើខុសច្បាប់(ឈើមានតម្លៃ)<br>**បុព្វហេតុប្រយោលៈ**<br>• ការអនុវត្តច្បាប់មានកម្រិត<br>• ភាពក្រីក្រ<br>• កំណើនប្រជាជន | • កម្មវិធីព្រៃឈើជាតិ<br>• ច្បាប់ EIA (ពង្រាង) អន្តរក្រសួង(សម្រាលផលប៉ះពាល់ឲ្យតិចបំផុត)<br>• ច្បាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ<br>• យុទ្ធសាស្រ្តគ្រប់គ្រងតំបន់ការពារធម្មជាតិ (ពង្រាង)<br>• គោលនយាបាយជាតិស្តីពីជលផល<br>• ច្បាប់ ស្តីពីជលផល<br>• ច្បាប់ ស្តីពីព្រៃឈើ<br>• ផែនការយុទ្ធសាស្រ្តវិស័យជលផល<br>• អនុក្រឹត្យស្តីពការកំណត់ព្រៃលិចទឹក |

| | |
|---|---|
| • ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ពន្ធ័(ផ្លូវភូមិ មន្ទីពេទ្យ)<br>• តម្រូវការឈើក្រៅស្រុក/ក្នុងស្រុក<br>• វារីអគ្គិសនី<br>• ខ្វះការគ្រប់គ្រង មិនមានផែនការគ្រប់គ្រង (ដកហូត)<br>• ខ្វះការកំណត់ព្រំប្រទល់តំបន់ព្រៃ<br>• តម្រូវការអុស ធ្យូង<br>• ខ្វះការចូលរួមពីអ្នកពាក់ពន្ធ័<br>• ខ្វះការគ្រប់គ្រង មិនមានផែនការគ្រប់គ្រង (ដកហូត និងជម្រុញការគ្រប់គ្រង)<br>• ខ្វះការកំណត់ព្រំប្រទល់តំបន់ព្រៃ(ជម្រុញការកំណត់ព្រំ ផ្សព្វផ្សាយ)<br>• តម្រូវការអុស ធ្យូង (ជីវឧស្ម័ន ចង្ក្រានសន្សំអុស ធ្យូងអនាម័យ)<br>• ខ្វះការចូលរួមពីអ្នកពាក់ពន្ធ័ (ផ្សព្វផ្សាយ លើកទឹកចិត្ត) | • អនុក្រឹត្យស្តីពីគោលការណ៍ណែនាំពីការបង្កើតរំសាយតំបន់គ្រប់គ្រងជលផល<br>• អនុក្រឹត្យបង្កើតសហគមន៍ព្រៃឈើ<br>• ការអនុវត្តច្បាប់មានកម្រិត(ពង្រឹងការអនុវត្តច្បាប់ និងអភិបាលកិច្ចល្អ)<br>• ភាពក្រីក្រ(បង្កើតមុខរបរ)<br>• សម្បទានដីសេដ្ឋកិច្ច/សង្គមកិច្ច(ពង្រឹងការត្រួតពិនិត្យEIA តាមដានការអនុវត្ត)<br>• កំណើនប្រជាជន(ផែនការប្រើប្រាស់ដី)<br>• ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ពន្ធ័(EIA និងការប្រើប្រាស់ដី)<br>• តម្រូវការឈើក្រៅស្រុក/ក្នុងស្រុក(ពង្រឹងការអនុវត្តច្បាប់ )<br>• ភ្លើងឆេះព្រៃ(ផ្លូវភ្លើង ផ្សព្វផ្សាយ)<br>• វារីអគ្គិសនី(EIA )<br>• អាជីវកម្មរ៉ែ(EIA ) |

**ចំណាត់អទិភាពក្នុងការដោះស្រាយ៖**

I )ការបាត់បង់ព្រៃឈើ៖

- រាជរដ្ឋាភិបាលត្រូវបញ្ឈប់ផ្តល់សម្បទានដីសេដ្ឋកិច្ច
- ទប់ស្កាត់ការកាប់រានដីព្រៃខុសច្បាប់ធ្វើកម្មសិទ្ធិ

II ) ការរេចរឹលព្រៃឈើ៖

- ទប់ស្កាត់ការកាប់ព្រៃឈើខុសច្បាប់
- ត្រូវដកហូតព្រៃឈើតាមបច្ចេកទេស
- បង្កើនប្រសិទ្ធិភាពគ្រប់គ្រងតាមរយៈសហគមន៍ព្រៃឈើ

III ) ការគ្រប់គ្រងព្រៃឈើដោយនិរន្តភាព៖

- បង្កើតសហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍នេសាទ
- ពង្រឹងការអនុវត្តន៍ច្បាប់

IV ) ការអភិរក្ស៖

- ពង្រឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ព្រៃការពារ និងព្រៃលិចទឹក
- ពង្រឹងសមត្ថភាពគ្រប់គ្រងរបស់សហគមន៍លើការអភិរក្ស

| |
|---|
| V ) បង្កើនបរិមាណកាបូនស្តុកក្នុងវិសាលភាពព្រៃឈើៈ<br>▪ បង្កើនការគ្រប់គ្រង និងការដាំដុះព្រៃក្នុងតំបន់សហគមន៍ និងព្រៃវិចរឹល<br><u>មិនត្រឹមតែដោះស្រាយបញ្ហាបាត់បង់ព្រៃឈើទេ៖</u><br>• ដីកសិកម្ម(ផែនការប្រើប្រាស់ដី)<br>• សម្បទានដីសេដ្ឋកិច្ច<br>• ជួយលើកតម្កើនជីវភាពប្រជាជន ដែលពឹងអាស្រ័យលើធនធានធម្មជាតិ<br>• ទប់ស្កាត់ចំណូលស្រុកខុសច្បាប់(ប្រជាជនពីក្រៅ)<br>• គួរតែចាប់ផ្តើមធ្វើរាល់សកម្មភាពខាងលើចាប់ពីពេលនេះតទៅ (ដោយសារតែការកាប់បំផ្លាញចេះតែបន្តមាននិងកើនឡើងជាគំហុក ហើយទិន្នន័យចាស់មានស្រាប់អាចមកប្រើបានជាបណ្តោះអាសន្ន)។<br>• ត្រូវតែអនុវត្តន៍ចាប់ពីថ្នាក់ក្រោមជាតិមុននឹងចាប់ផ្តើមអនុវត្តនៅថ្នាក់ជាតិ<br>(ដើម្បីទាញយកបទពិសោធន៍ បញ្ហាប្រឈមនិងភាពងាយស្រួល) |

**ក្រុមការងារបច្ចេកទេសចែករំលែកផលប្រយោជន៍៖**

**បង្ហាញដោយ៖ ចាន់ សុភាព**

| **ចលករដែលបណ្តាលអោយមានការបាត់បង់ និងរេចរឹលព្រៃឈើ** | **សកម្មភាព គោលនយោបាយ និងវិធានក្នុងការដោះស្រាយចលករទាំងនេះ** |
|---|---|
| **ចំណាត់អទិភាពក្នុងការដោះស្រាយ៖**<br>១. ការផ្តល់សម្បទានដីសេដ្ឋកិច្ច<br>២. ការរុករានដីព្រៃខុសច្បាប់ធ្វើកសិកម្ម និងលំនៅដ្ឋាន<br>៣. ការផ្តល់សម្បទានដីសង្គមកិច្ច<br>៤. ការធ្វើវាំរីអគ្គិសនី<br>៥. ការធ្វើអាជីវកម្មរ៉ែ | **ការបាត់បង់ខាងលើនេះត្រូវតែ៖**<br>១. សិក្សាបន្ថែមនិងគ្រប់គ្រងទិន្នន័យ និងធ្វើបច្ចុប្បន្នភាពច្បាស់លាស់<br><br>២. ត្រូវផ្សព្វផ្សាយព័ត៌មាន និងបង្ហាញទិន្នន័យបច្ចុប្បន្នភាពនៃការបាត់បង់ព្រៃឈើជាសាធារណៈ |
| **ដំណោះស្រាយ៖**<br>**ការផ្តល់ដីសម្បទានសេដ្ឋកិច្ច៖**<br>១. មានផែនការណ៍គ្រប់គ្រងដីសម្បទានសេដ្ឋកិច្ចច្បាស់លាស់<br>២. ត្រូវសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន(EI A)អោយបានច្បាស់លាស់ ដោយមានការចូលរួមនឹងទទួល<br>ខុសត្រូវពីអ្នកពាក់ព័ន្ធ | |

| |
|---|
| ៣. តាមដានផលប៉ះពាល់នៃការអនុវត្តអោយបានត្រឹមត្រូវ លើការអនុវត្តដីសម្បទានសេដ្ឋកិច្ច<br>៤. ពង្រឹងអភិបាលកិច្ច(ដីធ្លី)<br>៥. ពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធ |

**ក្រុមការងារបច្ចេកទេសអនុវត្តគំរូ៖**
**បង្ហាញដោយ៖**

| **ចលករដែលបណ្ដាលអោយមានការបាត់បង់ និងរេចរឹលព្រៃឈើ** | **សកម្មភាព គោលនយោបាយ និងវិធានក្នុងការដោះស្រាយចលករទាំងនេះ** |
|---|---|
| **ចំណាត់អទិភាពក្នុងការដោះស្រាយ៖**<br>១. រដ្ឋាភិបាលសម្បទានដីសេដ្ឋកិច្ចក្នុងកម្រិតខ្ពស់<br>២. រដ្ឋាភិបាលសម្បទានដីសង្គមកិច្ច<br>៣. ការទន្ទ្រានយកដីខុសច្បាប់<br>៤. ការសង់ទំនប់វារីអគ្គិសនី ការរុករករ៉ែ<br>៥. គ្មានផែនទី និងការចុះបញ្ជីដីធ្លីមិនច្បាស់លាស់<br>៦. ការសាងសង់ផ្លូវ<br>៧. ការកាប់ឈើខុសច្បាប់(ការរាន)<br>៨. ភ្លើងឆេះព្រៃ<br>៩. ការអនុវត្តច្បាប់នៅមានកំរិត<br>• ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរដ្ឋបាល (យោធា...)<br>• ទីផ្សារឈើ | • ពង្រឹងគោលនយោបាយដែលមានស្រាប់( NFP អនុក្រឹត្យដីសម្បទាន CF, PA Law,....)<br>• ការតាមដានអនុវត្តច្បាប់ (M&E)<br>• ការបង្កើត CF & CPAនិងCFi<br>• រៀបចំផែនទីប្រើប្រាស់ដីធ្លីច្បាស់លាស់ (អន្តរក្រសួង)<br>• FLEGT (ប្រភពឈើ Certificate<br>• ពង្រឹងការអនុវត្ត EIA |

**<u>សង្ខេបលទ្ធក្រុមពិភាក្សាទាំងបួន</u>**

| **ចលករដែលបណ្ដាលអោយមានការបាត់បង់ និងរេចរឹលព្រៃឈើ** | **សកម្មភាព គោលនយោបាយ និងវិធានក្នុងការដោះស្រាយចលករទាំងនេះ** |
|---|---|
| **<u>ការបាត់បង់ព្រៃឈើ៖</u>**<br>• ការបម្លែងដីព្រៃទៅជាដីមិនមែនព្រៃ | |

| | |
|---|---|
| សម្រាប់ដាំណាំឧស្សាហកម្មខ្នាតធំ និងមធ្យម តាមរយៈសម្បទានដីសេដ្ឋកិច្ច ការរុករករ៉ែ និង ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ<br><br>• ការបំលែងដីព្រៃទៅជាដីមិនមែនព្រៃខ្នាតតូច សម្រាប់លំនៅដ្ឋាន ដីកសិកម្មគ្រួសារ និងតំបន់អភិវឌ្ឍន៍ខ្នាតតូច តាមរយៈសម្បទានដីសង្គមកិច្ច<br><br>• ការកាប់រាន ឈូសឆាយ និងទន្ទ្រានយកដីព្រៃខុសច្បាប់<br><br>**<u>ការរេចរឹលព្រៃឈើ៖</u>**<br><br>• ការកាន់ឈើខុសច្បាប់<br><br>• ភ្លើងឆេះព្រៃ<br><br>• ការប្រមូលឈើថាមពលដោយគ្មាននិរន្តរភាព<br><br>**<u>បុព្វហេតុប្រយោលដែលបណ្តាលអោយមានការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ៖</u>**<br><br>• ការអនុវត្តច្បាប់មានកម្រិត<br>• ភាពក្រីក្រ<br>• កំណើនប្រជាជន<br>• ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ពន្ធ័(ផ្លូវ ភូមិ មន្ទីពេទ្យ...)<br>• តម្រូវការឈើក្រៅស្រុក/ក្នុងស្រុក | • ពង្រឹងគោលនយោបាយគ្រប់គ្រងក្នុងវិស័យព្រៃឈើ និងដីព្រៃដែលមានស្រាប់ដើម្បីធានាថា គោលនយោបាយទាំងនេះអាចសម្រេចតាមគោលដៅ ដូចជា៖ NFP(2009-2019), SPFF និងPASP។<br><br>• ពង្រឹងគោលនយោបាយដីធ្លីក្រៅពីវិស័យព្រៃឈើ៖<br>ក. ពង្រឹងការអនុវត្តច្បាប់ EIA<br>ខ. ពង្រឹងការអនុវត្តអនុក្រឹត្យ ELC នឹងSLC<br>គ. ពង្រឹងការអនុវត្តអភិបាលកិច្ចព្រៃឈើ និងការអនុវត្តច្បាប់<br>ឃ. ពង្រឹងការអនុវត្ត<br>ង. ធ្វើអោយប្រសើរទាំងការអនុវត្ត និងរៀបចំគោលនយោបាយផែនការប្រើប្រាស់ដីធ្លីថ្នាក់ក្រោមជាតិ។ |

| | |
|---|---|
| • ខ្វះការគ្រប់គ្រង មិនមានផែនការគ្រប់គ្រង(ដកហូត)ឈើប្រកបដោយនិរន្តរភាព<br>• ខ្វះការកំណត់ព្រំប្រទល់តំបន់ដីព្រៃ<br>• តម្រូវការអុស ធ្យូង<br>• ខ្វះការចូលរួមពីអ្នកពាក់ពន្ធ័<br>• ខ្វះការគ្រប់គ្រង មិនមានផែនការគ្រប់គ្រង(ដកហូត)(ជម្រុញការគ្រប់គ្រង)<br>• ខ្វះការកំណត់ព្រំប្រទល់តំបន់ដីព្រៃ(ជម្រុញការកំណត់ព្រំ ផ្សព្វផ្សាយ)<br>• តម្រូវការអុស ធ្យូង(ជីវឧស្មន័ ចង្ក្រានសន្សំអុស ធ្យូងអនាម័យ)<br>• ខ្វះការចូលរួមពីអ្នកពាក់ពន្ធ័(ផ្សព្វផ្សាយលើកទឹកចិត្ត) | |

**លោក ជុំ សុវណ្ណីៈ**

- ស្ថាប័នរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាធ្លាប់មានបទពិសោធន៍នៅក្នុងការរៀបចំយុទ្ធសាស្រ្ត និងកម្មវិធីជាតិ ជាច្រើន ដូចជា កម្មវិធីព្រៃឈើជាតិ(2010-2029) ផែនការយុទ្ធសាស្រ្តគ្រប់គ្រងវិស័យជលផល និងផែនការយុទ្ធសាស្រ្តប្រែប្រួលអាកាសធាតុ។ ប៉ុន្តែក៏មានផែនការយុទ្ធសាស្រ្តមួយចំនួនដែលមិនអាចរៀបចំបានជោគជ័យឡើយ ដូចជាផែនការសកម្មភាពសម្រាប់ដោះស្រាយការរេចរឹលដី(២០០៩) ដូចនេះយើងគួររៀនសូត្រពីបទពិសោធន៍ទាំងនេះ។

- ការរៀបចំយុទ្ធសាស្រ្តរេដបូកជាតិ គឺមិនត្រឹមតែបំពេញនូវតម្រូវការរបស់ជាតិប៉ុណ្ណោះទេ ថែមទាំងបំពេញនូវតម្រូវការរបស់អន្តរជាតិ ជាពិសេសការរៀបចំនេះគួរផ្អែកលើកិច្ចចរចារ ស្តីពី រេដបូកក្រោមអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ យើងមានការចូលរួមពីតំណាងអង្គការ UNDP ថ្នាក់តំបន់ និងអ្នកជំនាញការបរទេសផ្សេងៗទៀត ពួកគាត់អាចផ្តល់យោបល់លើឯកសារយុទ្ធសាស្រ្តនេះ នឹងអាចជាសាក្សីសម្រាប់អន្តរថាយុទ្ធសាស្រ្តរេដបូកជាតិនេះរៀបចំឡើងដោយមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ជាពិសេសនៅក្នុងកិច្ចប្រជុំប្រទេសជាភាគគីនៅប្រទេសបារាំងនាខែធ្នូ ឆ្នាំ២០១៥ ខាងមុខ។

- កិច្ចពិគ្រោះយោបល់នេះយើងពិភាក្សាលើជំពូកទី១ ដល់ជំពូកទី៤ តែជំពូកទី៥ ដល់ជំពូកទី៩ នឹងលើកយកមកពិភាក្សាម្តងទៀតនៅខេត្តសៀមរាប។ ប៉ុន្តែយើងក៏បានទទួលនូវធាតុចូលសំខាន់ៗមួយចំនួនពីក្រុមប្រឹក្សាយោបល់រេដបូក និងសហគមន៍ជនជាតិដើមភាគតិចតាមរយៈកិច្ចពិគ្រោះយោបល់ ទាក់ទងនឹងប្រព័ន្ធធានាសុវត្ថិភាពរេដបូក។ ចំពោះជំពូកដែលបង្ហាញ ស្តីពី ប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិ និងកម្រិតបំភាយយោងព្រៃឈើយើងនៅមិនទាន់បានពិគ្រោះយោបល់អោយបានស៊ីជម្រៅនៅឡើយទេ។

- ចំពោះប្រទេសដែលបានអនុវត្តរេដបូកមួយចំនួន គេមិនចាំបាច់រងចាំការរៀបចំយុទ្ធរេដបូកជាតិមួយអោយល្អឥតខ្ចោះនោះទេ រដ្ឋាភិបាលនៃប្រទេសទាំងនោះគ្រាប់តែបំពេញនូវតម្រូវដែលទាបបំផុតរបស់ជាតិ និងអន្តរជាតិ ហើយប្រើប្រាស់យុទ្ធសាស្ត្រនេះជាឧបករណ៍ ដើម្បីទាក់ទាញមូលនិធិអន្តរជាតិសម្រាប់អនុវត្តរេបបូកនៅក្នុងប្រទេសរបស់ពួកគេ នៅពេលពួកគាត់ទទួលបានមូលនិធិហើយពួកគេនឹងធ្វើការកែរសម្រួលយុទ្ធសាស្ត្ររេដបូកជាតិពួកគេអោយប្រសើរជាងមុន។

**សុន្ទរកថាបិទអង្គសិក្ខាសាលារបស់ លោកបណ្ឌិត ដោក ដូម៉ា** ក្រុមការងាររេដបូកជាតិប្រធានក្រុមការងាររេដបូកកម្ពុជា និងជាអនុប្រធាននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទដែលមានអត្ថន័យនិងខ្លឹមសារសំខាន់ៗដូចខាងក្រោមៈ

កិច្ចប្រជុំដែលបានរៀបចំនេះពិតជាមានអត្ថន័យ នឹងបានឆ្លុះបញ្ចាំងពីទស្សនៈ និងធាតុចូលរបស់អ្នកពាក់ព័ន្ធនានា ទៅលើសេចក្តីព្រាងលើទី២នៃយុទ្ធសាស្ត្ររេដបូកជាតិនេះ ពីកិច្ចពិគ្រោះយោបល់មួយទៅកិច្ចប្រជុំពិគ្រោះយោបល់មួយវាបានធ្វើអោយយុទ្ធសាស្ត្រជាតិមួយនេះកាន់តែប្រសើរឡើងៗ។ ក្រុមការងាររេដបូកជាតិនឹងចូលរួម និងគាំទ្រនូវសកម្មភាពិគ្រោះយោបល់នេះបន្តរទៀត។ យុទ្ធសាស្ត្ររេដបូកជាតិមួយនេះពិតជាបានឆ្លើយតបនូវតម្រូវការរបស់អន្តរជាតិជាពិសេសក្រោមអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ និងបានឆ្លុះបញ្ចាំងនូវកាលៈទេសៈរបស់យើងផងដែរ។